# មេរៀនសង្ខេប

- ក្រពេញមានពីរប្រភេទ។ ក្រពេញអិចសូគ្រីនបញ្ចេញរសតាមបំពង់នាំនិងក្រពេញអង់ដូគ្រីនបញ្ចេញអរម៉ូនទៅក្នុងចរន្តឈាមដោយផ្ទាល់ ។ អរម៉ូនជាសារធាតុគីមី ដែលមានឥទ្ធិពលទៅ លើមេតាបូលីសនៃកោសិកាគោលដៅ ។
- អរម៉ូនមានពីរក្រុម : អរម៉ូនប៉ិបទីតនិងអរម៉ូនស្តេរ៉ូអ៊ីត។ អរម៉ូនប៉ិបទីតធ្វើឱ្យអង់ស៊ីមក្នុងកោសិកាគោលដៅសកម្មឡើង។ អរម៉ូនស្តេរ៉ូអ៊ីតភ្ញោចសែនក្នុងកោសិកាគោលដៅសកម្មឡើង ដើម្បីសំយោគប្រូតេអ៊ីនចាំបាច់ ។
- សកម្មភាពរបស់ក្រពេញអង់ដូគ្រីនត្រូវបានត្រួតពិនិត្យដោយចលនការតំណបត្រឡប់អវិជ្ជមាន។តាមរយៈតំណបត្រឡប់អវិជ្ជមាន កំហាប់របស់សារធាតុមួយចំនួននៅក្នុងឈាមពន្លឿន ឬបង្អាក់ការបញ្ចេញរបស់ក្រពេញ ។
- អ៊ីប៉ូតាឡាមុសផលិតអរម៉ូនពីរគឺ ADH និងអុកស៊ីតូស៊ីន ដែលត្រូវបានស្តុកទុកក្នុងអ៊ីប៉ូភីសក្រោយ ។ ADH ភោចតម្រងនោមឱ្យមានជម្រាបទឹកចេញឡើងវិញ។ ឯអុកស៊ីតូស៊ីនភ្ញោចស្បូនឱ្យកន្ត្រាក់ក្នុងរយៈពេលសម្រាលកូន ។
- អ៊ីប៉ូភីសមុខផលិតយ៉ាងតិចអរម៉ូន 6 បែប ។ GH ជំរុញការលូតលាស់នៃសារពាង្គកាយ ។ ប្រូឡាក់ទីនជំរុញការលូតលាស់ទ្រូងនិងផលិតទឹកដោះ បន្ទាប់ពីសម្រាលកូន ។ MSH ភ្ញោច កោសិកាមេឡាណូស៊ីតនៃស្បែក ឱ្យផលិតមេឡានីន ។ TSH ភោចក្រពេញទីរ៉ូអ៊ីត ឱ្យផលិតទីរ៉ុកស៊ីន ACTH ភ្ញោចករតិចលើតម្រងនោម ឱ្យផលិតអរម៉ូនករទីសូល។
- ក្រពេញទីរ៉ូអ៊ីតតម្រូវអត្រាមេតាបូលីសកោសិកានិងបន្ថយកម្រិតកាល់ស្យូមនៅក្នុងឈាម ។ អរម៉ូនប៉ារ៉ាទីរ៉ូអ៊ីតតម្រូវមេតាបូលីសកាល់ស្យូមនិងផូស្វាត ។
- ក្រពេញខួរលើតម្រងនោមបញ្ចេញអេពីណេព្រីននិងណូអេពីណេព្រីនដែលនាំមកនូវតំណបជាមួយប្រតិកម្មទប់ទល់និងគេចចេញ ។
- ករតិចលើតម្រងនោមផលិតករទីសូលនិងអាល់ដូស្តេរ៉ូន ។ ករទីសូលភ្ញោចអ៊ីដ្រូលីសប្រូតេអ៊ីន និងលីពីតឱ្យទៅជាអាស៊ីតអាមីណេនិងអាស៊ីតខ្លាញ់ បន្ទាប់មកបំប្លែងជាគ្លុយស៊ីត។ ករណីនេះបង្កើនកម្រិតគ្លុយកូសក្នុងឈាម។ អាល់ដូស្តេរ៉ូនធ្វើឱ្យតម្រងនោមមានជម្រាបសូដ្យូមចេញវិញ និងបញ្ចេញប៉ូតាស្យូមចោល។
- លំពែងផលិតអាំងស៊ុយលីននិងគ្លុយកាកុង ។ អាំងស៊ុយលីនបន្ថយអត្រាគ្លុយកូសក្នុងឈាម គ្លុយកាកុងបង្កើនកម្រិតគ្លុយកូសក្នុងឈាម។